# ហំសជាតក




*ព្រះសាស្តា កាលស្តេចគង់នៅវត្តវេឡុវ័ន ទ្រង់ការបរិច្ចាគជីវិត របស់ព្រះអានន្ទថេរៈ បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* **ឯតេ ហំសា បក្កមន្តិ** *ដូច្នេះជាដើម ។*

*គ្រានោះ កាលភិក្ខុទាំងឡាយកំពុងពោលគុណកថារបស់ព្រះអានន្ទថេរៈក្នុងធម្មសភា ព្រះសាស្តាយាងមក ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយ អង្គុយប្រជុំគ្នាដោយរឿងអ្វី? កាលពួកភិក្ខុទូលថា ដោយរឿងឈ្មោះនេះ ទ្រង់ត្រាស់ថា ម្នាល ភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុន អានន្ទក៏បានបរិច្ចាគជីវិត ដើម្បីតថាគតដែរ ដូច្នេះហើយ ព្រះអង្គក៏បាននាំអតីតនិទានមកសម្តែងថា*

*ក្នុងអតីតកាល ព្រះរាជាព្រះនាម* ***ពហុបុត្តកៈ*** *សោយរាជសម្បត្តិក្នុងនគរពារាណសី។ ព្រះអគ្គមហេសីរបស់ព្រះរាជានោះមានព្រះនាមថា* ***ខេមា*** *។ គ្រានោះ ព្រះមហាសត្វសោយ*

ព្រះជាតិជាសុវណ្ណហង្ស មាន ៩០០០០ ជាបរិវារ រស់នៅលើភ្នំចិត្តកូដ ។ សូម្បីក្នុងគ្រានោះ ព្រះទេវីក៏យល់ព្រះសុបិន ឃើញដោយន័យដូចពោលមកហើយនោះដែរ ។ ចំណែកព្រះរាជាត្រាស់សួរពួកអាមាត្យ និងបានស្ដាប់ថា មានហង្សពណ៌មាសរស់នៅនឹងភ្នំចិត្តកូដ ដូច្នេះហើយ ទ្រង់ក៏គេធ្វើស្រះឈ្មោះខេមៈ បញ្ជាឲ្យគេដាំបន្លែ និងធញ្ញជាតិផ្សេងៗ ត្រាស់ឲ្យឃោសនាការប្រកាសប្រទានអភ័យ រាល់ៗថ្ងៃ ក្នុងមុំស្រះទាំងបួន និងបញ្ជាលុទ្ទបុត្រម្នាក់ឲ្យប្រកបកិច្ចការចាប់ពួកហង្ស ។ អាការប្រកបកិច្ចការរបស់ព្រាននោះ និងការពិចារណារបស់ពួកបក្សីក្នុងស្រះនោះក្ដី និយាមនៃការដាក់អន្ទាក់ ក្នុងវេលាដែលសុវណ្ណហង្សមក ហើយក្រាបទូលព្រះរាជាក្ដី និយាមនៃការជាប់អន្ទាក់របស់ព្រះមហាសត្វក្ដី ការវិលត្រឡប់របស់សុមុខហង្សសេនាបតីដែលមិនឃើញព្រះមហាសត្វ ក្នុងហ្វូងហង្សទាំង ៣ នោះក្ដី ទាំងអស់នេះ នឹងមានជាក់ច្បាស់ ក្នុង**មហាហំសជាតក** (អសីតិនិបាត) ។

ចំណែកព្រះមហាសត្វកាលជាប់អន្ទាក់ហើយ ក៏តោងជង់អន្ទាក់ លាតកចេញ សម្លឹងមើលផ្លូវដែលពួកហង្សទៅ ឃើញហង្សសុមុខកំពុងមក ទើបគិតថា កាលសុមុខហង្សមកដល់យើងនឹងសាកល្បង ដូច្នេះកាលសុមុខសេនាបតីមកដល់ ក៏ពោល ៣ គាថាថា

**ឯតេ ហំសា បក្កមន្តិ, វក្កង្គា ភយមេរិតា;**
**ហរិត្តច ហេមវណ្ណ, កាមំ សុមុខ បក្កម។**

ពួកហង្ស មានកកួកទាំងនេះ លុះត្រូវភ័យគ្របសង្កត់ហើយ ក៏ហើរអស់ទៅ ម្នាល សុមុខៈ មានសមប្បុរដូចមាស អ្នកចូរគៀសខ្លួនទៅចុះ ។

**ឱហាយ មំ ញាតិគណា, ឯកំ បាសវសំ គតំ;**
**អនបេក្ខមានា គច្ឆន្តិ, កិំ ឯកោ អវហិយ្យសិ។**

ពួកបក្សីជាញាតិលះបង់នូវយើងម្នាក់ឯង ដែលលុះអំណាចអន្ទាក់ ឥតមានអាឡោះអាល័យហើរទៅហើយ ខ្លួនអ្នកតែម្នាក់ឯង សម្ងំនៅដូចម្ដេចបាន ។

បតេវ បតតំ សេដ្ឋ, នត្ថិ ពទ្ធេ សហាយតា;
អនីឃាយ ហាបេសិ, កាមំ សុមុខ បក្កម។

*ការដែលហើរចេញទៅ របស់ពួកសត្វស្លាប ជាការប្រសើរ ការប្រព្រឹត្តនៅជាមួយអ្នកដែលជាប់ចំណង ជាការប្រសើរ មិនមែនទេ អ្នកកុំធ្វើសេចក្តីព្យាយាមឲ្យសាបសូន្យ ដោយសេចក្តីទុក្ខឡើយ ម្នាលសុមុខៈ អ្នកចូរកៀសខ្លួនចេញទៅតាមប្រាថ្នាចុះ ។*

*លំដាប់នោះ សុមុខហង្សទំលើកក់ ពោលគាថាថា*

នាហំ ទុក្ខបរេតោតិ, ធតរដ្ឋ តុវំ ជហេ;
ជីវិតំ មរណំ វា មេ, តយា សទ្ធិំ ភវិស្សតិ។

*បពិត្រស្តេចហង្សឈ្មោះធតរដ្ឋ ព្រះអង្គត្រូវសេចក្តីទុក្ខគ្របសង្កត់ហើយ ខ្ញុំព្រះអង្គមិនលះបង់ចោលព្រះអង្គទេ ការរស់ឬការស្លាប់របស់ខ្ញុំព្រះអង្គ នឹងមាននៅជាមួយព្រះអង្គ ។*

*កាលហង្សសុមុខៈពោលសីហនាទយ៉ាងនេះហើយ ស្តេចហង្សធតរដ្ឋៈពោលគាថាថា*

ឯតទរិយស្ស កល្យាណំ, យំ ត្វំ សុមុខ ភាសសិ;
តញ្ច វីមំសមានោហំ, បតតេតំ អវស្សជឹ។

*ម្នាលសុមុខៈ អ្នកពោលនូវពាក្យណា ពាក្យនុ៎ះជាពាក្យល្អរបស់អរិយជន ចំណែកខាងខ្ញុំល្បងមើលអ្នកក្នុងការហើរចេញទៅ ទើបពោលពាក្យ ( យ៉ាងនេះ) នឹងអ្នក ។*

*កាលហង្សទាំងពីរកំពុងពោលយ៉ាងនេះហើយ លុទ្ទបុត្រកាន់ដំបង ស្ទុះចេញមកដោយរហ័ស ។ សុមុខហង្សល្អួងលោមធតរដ្ឋហង្សហើយ មានមុខបែរទៅរកព្រាននោះ សម្តែងអបចាយនៈ រួចពោលគុណរបស់ស្តេចហង្ស ។ ក្នុងពេលនោះ ព្រានក៏មានចិត្តទន់ ។*

*សុមុខហង្សដឹងថា ព្រានមានចិត្តទន់ហើយ ទើបទៅលួងលោមស្តេចហង្សម្តងទៀត ។ ចំណែកព្រានចូលទៅរករាជហង្សហើយពោលគាថាទី ៦ ថា*

អបរេន បទំ យាតិ, អន្តលិក្ខចរោ ទិជោ;
អារា ចាសំ ន ពុជ្ឈិ ត្វំ, ហំសានំ បវរុត្តម។

*សត្វបក្សីជាសត្វត្រេចទៅក្នុងអាកាស រមែងទៅកាន់ផ្លូវតាមអាកាស ដែលមិនមែនជាផ្លូវ ម្នាលអ្នកដ៏ប្រសើរជាងពួកបក្សីហង្ស ( ម្តេចក៏) អ្នកមិនដឹងនូវអន្ទាក់អំពីចម្ងាយ ។*

*ព្រះមហាសត្វពោលថា*

យទា បរាភវោ ហោតិ, បោសោ ជីវិតសង្ខយេ;
អថ ជាលញ្ច បាសញ្ច, អាសជ្ជាបិ ន ពុជ្ឈតិ។

*សេចក្តីវិនាសមានមក ក្នុងកាលណា សត្វកាលបើជីវិតត្រូវអស់ហើយ ទោះបីប្រទះនូវសំណាញ់ ឬអន្ទាក់រមែងមិនដឹង ក្នុងកាលនោះ ។*

*ពាក្យថា **សេចក្តីវិនាសមានមក ក្នុងកាលណា** សេចក្តីថា នៃលុទ្ទបុត្រសម្លាញ់ សេចក្តីវិនាស សេចក្តីមិនចម្រើន សេចក្តីអន្តរាយ កើតឡើងក្នុងកាលណា សត្វដែលដល់ការអស់ជីវិត កាលដល់សំណាញ់ក្តី អន្ទាក់ក្តី រមែងមិនដឹង ។*

*ព្រានត្រេកអរនឹងពាក្យរបស់ស្តេចហង្សហើយ កាលចរចាមួយអន្លើដោយសុមុខហង្ស ទើបពោល ៣ គាថាថា*

ឯតេ ហំសា បក្កមន្តិ, វក្កង្គា ភយមេរិតា;
ហរិត្តច ហេមវណ្ណ, ត្វញ្ញេវ អវហិយ្យសិ។

ពួកបក្សីហង្សមានកក្អក់ទាំងនេះ លុះត្រូវភ័យគ្របសង្កត់ហើយ ក៏ហើរអស់ទៅ ម្នាលអ្នកមានស្បែកដ៏ខៀវ មានវណ្ណៈដូចមាស អ្នកម្នាក់ឯងសម្ងំនៅ ។

ឯតេ ភុត្វា ច បិវិត្វា ច, បក្កមន្តិ វិហង្គមា;
អនបេក្ខមានា វក្កង្គា, ត្វញ្ញេវេកោ ឧបាសសិ។

ពួកបក្សីទាំងនេះ ជាសត្វទៅតាមអាកាស ឥតមានអាល័យ ជាសត្វមានកក្អក់ លុះស៊ីហើយ ផឹកហើយ ក៏ហើរចេញទៅ អ្នកតែម្នាក់ឯងចូលមកវិញ ។

កិំ នុ ត្យាយំ ទិជោ ហោតិ, មុត្តោ ពទ្ធំ ឧបាសសិ;
ឱហាយ សកុណា យន្តិ, កិំ ឯកោ អវហិយ្យសិ។

បក្សីនេះត្រូវជាអ្វីនឹងអ្នក ទើបអ្នកដែលផុត ( ចាកអន្ទាក់ ) ចូលមករកបក្សីដែលជាប់វិញ ពួកបក្សីនាំគ្នាហើរចោលអស់ទៅហើយ ហេតុដូចម្ដេច អ្នកសម្ងំនៅតែម្នាក់ឯង ។

ហង្សសុមុខសេនាបតីពោលថា

រាជា មេ សោ ទិជោ មិត្តោ, សខា បាណសមោ ច មេ;
នេវ នំ វិជហិស្សាមិ, យាវ កាលស្ស បរិយាយំ។

បក្សីនេះជាស្ដេចរបស់យើងផង ជាមិត្ររបស់យើងផង ជាសម្លាញ់ស្មើដោយជីវិតរបស់យើងផង ខ្លួនយើងនឹងមិនលះបង់នូវបក្សីនោះ ដរាបដល់អស់កាលនៃជីវិត ។

ព្រានព្រៃស្ដាប់ពាក្យនោះហើយ មានចិត្តជ្រះថ្លា រួចគិតថា បើយើងបៀតបៀនសត្វដែលដល់ព្រមដោយសីលយ៉ាងនេះ សូម្បីផែនដីក៏នឹងគប្បីឲ្យប្រហោងដល់យើង ( ផែន

ជីស្រូប) ប្រយោជន៍អ្វី ដោយទ្រព្យដែលយើងត្រូវបានពីសម្នាក់ព្រះរាជានោះ យើងដោះលែងហង្សនេះ ដូច្នេះទើបពោលគាថាថា

**យោ ច ត្វំ សខិនោ ហេតុ, ចាណំ ចជិតុមិច្ឆសិ;**
**សោ តេ សហាយំ មុញ្ចាមិ, ហោតុ រាជា តវានុគោ។**

*អ្នកណាប្រាថ្នាលះបង់ជីវិត ព្រោះហេតុសម្លាញ់ យើងនឹងលែងនូវសម្លាញ់របស់អ្នកនោះ ក្នុងកាលឥឡូវនេះ សូមឲ្យស្ដេចរបស់អ្នកទៅជាមួយនឹងអ្នកចុះ ។*

កាលព្រានពោលយ៉ាងនេះហើយ គាត់ក៏ដាក់ស្ដេចហង្សធតរដ្ឋៈចុះពីដងអន្ទាក់ នាំយកកាន់ប្រាំងស្រះ រួចដោះអន្ទាក់ចេញ លាងឈាមដោយចិត្តទន់ ព្យាបាលរបួសដោយរៀបចំដាក់សរសៃជាដើមឡើងវិញ ។ ដោយចំណាចចិត្តទន់របស់នាយព្រាន និងដោយអានុភាពបារមីរបស់ព្រះមហាសត្វ ក្នុងពេលនោះឯង ដំបៅជើងព្រមទាំងស្បែកសម្បុរថ្ងៃក៏ជាសះស្បើយ ជិតជាប់គ្នាវិញ មិនប្រាកដដោយស្លាកស្នាម ។

សុមុខហង្សសម្លឹងមើលព្រះពោធិសត្វ ហើយមានចិត្តត្រេកអរ កាលធ្វើការអនុមោទនា ទើបពោលគាថាថា

**ឯវំ លុទ្ទក នន្ទស្សុ, សហ សព្ពេហិ ញាតិភិ;**
**យថាហមជ្ជ នន្ទាមិ, មុត្តំ ទិស្វា ទិជាធិបំ។**

*ម្នាលព្រាន ក្នុងថ្ងៃនេះ យើងត្រេកអរព្រោះបាន ឃើញនូវស្ដេចបក្សីរួចចាកចំណងយ៉ាងណា អ្នកក៏ចូរត្រេកអរជាមួយញាតិទាំងអស់ យ៉ាងនោះដែរ ។*

*ព្រានព្រៃស្តាប់ពាក្យនោះហើយ ពោលថា បពិត្រលោកម្ចាស់ លោកចូរទៅចុះ ។ លំដាប់នោះ ព្រះមហាសត្វសួរព្រានថា នែសម្លាញ់ អ្នកចាប់យើងដោយប្រយោជន៍របស់ខ្លួន ឬដោយការបង្គាប់របស់អ្នកដទៃ ? កាលព្រាននោះប្រាប់ហេតុរួចហើយ ទើបព្រះពោធិសត្វពិចារណាថា យើងគប្បីទៅក្នុំចិត្តកូដ ឬក៏ទៅនគរ ទើបជាការប្រសើរ ដូច្នេះហើយ ស្តេចហង្សធ្វើសេចក្តីសន្និដ្ឋានថា កាលយើងទៅនគរ លុទ្ទបុត្រនឹងបានទ្រព្យ ហើយចំណង់ប្វែករបស់ព្រះទេវីក៏នឹងស្ងប់រម្ងាប់, មិត្តធម៌របស់សុមុខហង្សនឹងបានប្រាកដ ហើយញាណពលៈរបស់យើងក៏នឹងប្រាកដដែរ យើងនឹងបានធ្វើខេមស្រះឲ្យជាទីឲ្យអភ័យ ព្រោះហេតុនោះ យើងគប្បីទៅកាន់នគរប៉ុណ្ណោះ ទើបជាការប្រសើរ ដូច្នេះហើយ ស្តេចហង្សពោលថា នែព្រាន អ្នកចូរនាំយើងដោយអម្រែក ទៅកាន់សម្នាក់ព្រះរាជា បើព្រះរាជាមានសេចក្តីប្រាថ្នាដោះលែងយើង សឹមអ្នកដោះលែងយើងចុះ ។ ព្រានពោលថា បពិត្រលោកម្ចាស់ ធម្មតា ព្រះរាជាទាំងឡាយជាមនុស្សកាចរឹងរូស សូមលោកទៅចុះ ។ ហង្សធតរដ្ឋៈពោលថា សូម្បីព្រានដែលមានសភាពដូចអ្នក ក៏ពួកយើងធ្វើឲ្យទន់បាន ការធ្វើឲ្យព្រះរាជាមានសេចក្តីត្រេកអរ ជាភារៈរបស់យើង នែសម្លាញ់ ចូរនាំពួកយើងទៅចុះ ។ ព្រានក៏បានធ្វើយ៉ាងនោះ ។ ព្រះរាជាឃើញហង្សហើយ កើតសេចក្តីសោមនស្ស ឲ្យគេដាក់ហង្សទាំងពីរឲ្យទំលើតាំងមាស ឲ្យហង្សបរិភោគលាជដែលលាយដោយទឹកឃ្មុំ និងឲ្យផឹកទឹកដែលមានរសផ្អែម រួចព្រះអង្គផ្គងអញ្ជលីសូមធម្មកថា ។ ស្តេចហង្សដឹងភាពជាអ្នកប្រាថ្នានឹងស្តាប់របស់ព្រះរាជាហើយ ទើបធ្វើបដិសណ្ឋារៈ ជាដំបូង ។*

*តទៅនេះ ជាគាថាឆ្លងឆ្លើយរបស់ស្តេចហង្ស និងព្រះរាជា ៖*

*(ស្តេចហង្សពោលថា)*

**កច្ចិន្នុ ភោតោ កុសលំ, កច្ចិ ភោតោ អនាមយំ;**
**កច្ចិ រដ្ឋមិទំ ផីតំ, ធម្មេន មនុសាសសិ។**

*ព្រះអង្គមានសេចក្ដីសុខស្រួលទេឬ ព្រះអង្គមិនមាន ជំងឺតម្កាត់ទេឬ ព្រះអង្គតែងប្រៀនប្រដៅ នូវអ្នកដែនដ៏ធំទូលាយនេះ តាមធម៌ទេឬ ។*

*( ព្រះរាជាតបថា )*

កុសលំ ចេវ មេ ហំស, អថោ ហំស អនាមយំ;
អថោ រដ្ឋមិទំ ផីតំ, ធម្មេន មនុសាសហំ។

*ម្នាលហង្ស យើងមានសេចក្ដីសុខស្រួលទេ ម្នាលហង្ស យើងមិនមានជំងឺតម្កាត់ទេ ខ្លួនយើងក៏បានប្រៀនប្រដៅ នូវអ្នកដែនដ៏ធំនេះ តាមធម៌ ។*

*( ស្ដេចហង្សសួរថា )*

កច្ចិ ភោតោ អមច្ចេសុ, ទោសោ កោចិ ន វិជ្ជតិ;
កច្ចិ អារា អមិត្តា តេ, ឆាយា ទក្ខិណតោរិវ។

*ពួកអាមាត្យរបស់ព្រះអង្គ មិនមានកំហុសណាមួយ ទេឬ ពួកសត្រូវនៃព្រះអង្គក្នុងទីឆ្ងាយ ដូចជាស្រមោល ( ដែលមិនមាន ) ក្នុងទិសខាងត្បូងទេឬ ។*

*( ព្រះរាជាតបថា )*

អថោបិ មេ អមច្ចេសុ, ទោសោ កោចិ ន វិជ្ជតិ;
អថោ អារា អមិត្តា មេ, ឆាយា ទក្ខិណតោរិវ។

*ពួកអាមាត្យរបស់យើង មិនមានកំហុសណាមួយទេ ទាំងសត្រូវរបស់យើងក្នុងទីឆ្ងាយ ក៏ដូចស្រមោល ( ដែលមិនមាន ) ក្នុងទិសខាងត្បូង ដូច្នោះ ។*

*(ស្តេចហង្សសួរថា)*

កច្ចិ តេ សាទិសី ភរិយា, អស្សវា បិយភាណិនី;
បុត្តរូបយសូបេតា, តវ ឆន្ទវសានុគា។

*ភរិយារបស់ព្រះអង្គមានចិត្តស្មើគ្នា ជាស្រីស្តាប់បង្គាប់ព្រះអង្គ ស្រដីនូវពាក្យជាទីស្រឡាញ់ បរិបូណ៌ដោយបុត្តនិងរូបនិងយសបរិវារ លុះអំណាចសេចក្តីប្រាថ្នារបស់ព្រះអង្គដែរឬ។*

*(ព្រះរាជាតបថា)*

អថោ មេ សាទិសី ភរិយា, អស្សវា បិយភាណិនី;
បុត្តរូបយសូបេតា, មម ឆន្ទវសានុគា។

*ភរិយារបស់យើងមានចិត្តស្មើគ្នា ជាស្រីស្តាប់បង្គាប់យើង ស្រដីពាក្យជាទីស្រឡាញ់ ប្រកបដោយបុត្តនិងរូបនិងយសបរិវា លុះ អំណាចសេចក្តីប្រាថ្នារបស់យើងទេ។*

*(ស្តេចហង្សសួរថា)*

កច្ចិ តេ ពហវោ បុត្តា, សុជាតា រដ្ឋវឌ្ឍន;
បញ្ញាជវេន សម្បន្នា, សម្មោទន្តិ តតោ តតោ។

*បពិត្រព្រះអង្គ អ្នកញាំងដែនឲ្យចម្រើន ព្រះអង្គមានព្រះរាជបុត្តច្រើន កើតឡើងដោយល្អ បរិបូណ៌ដោយសន្ទុះនៃប្រាជ្ញា ស្រុះស្រួលរកគ្នា ក្នុងហេតុនោះៗ ដែរឬ។*

*(ព្រះរាជាតបថា)*

សតមេកោ ច មេ បុត្តា, ធតរដ្ឋ មយា សុតា;
តេសំ ត្វំ កិច្ចមក្ខាហិ, ជាវុជ្ឈន្តិ តេ វចោ។

*ម្នាលស្ដេចហង្សឈ្មោះធតរដ្ឋ យើងមានកូនមួយរយនាក់ ដែលអ្នកផងឮសុះសាយថា យើងជាអ្នក (មានកូនច្រើន) កូនទាំងនោះ រមែងមិនខឹងនឹងសំដីរបស់អ្នកទេ សូមអ្នកប្រាប់នូវអំពើ ដែលត្រូវធ្វើដល់កូនទាំងនោះចុះ ។*

*បទថា* **កុសលំ** *បានដល់* **អារោគ្យៈ** *(ការមិនមានរោគ) ជាវេវចនៈណាមួយដទៃទៀត របស់កុសលនោះ ។*

*ព្រះមហាសត្វស្ដាប់ពាក្យនោះហើយ កាលថ្វាយឱវាទដល់ព្រះរាជា ទើបពោល ៥ គាថាថា*

ឧបបន្នោបិ ចេ ហោតិ, ជាតិយា វិនយេន វា;
អថ បច្ឆា គុរុតេ យោគំ, កិច្ចេ អាចាសុ សីទតិ។

*បុគ្គលបើទុកជាបរិបូណ៌ដោយជាតិនិងច្បាប់ តែបើក្នុងកាលជាខាងក្រោយ គឺកាលដែលខ្លួនចាស់ ធ្វើនូវសេចក្ដីព្យាយាមក្នុងកិច្ចការ រមែងលិចចុះក្នុងសេចក្ដីអន្តរាយ ។*

តស្ស សំហីរបញ្ញស្ស, វិវរោ ជាយតេ មហា;
រត្តិមន្ធោវ រូបានិ, ថូលានិ មនុបស្សតិ។

*កាលបុគ្គលចាស់នោះ មានប្រាជ្ញាវេវរាយ ទោសក៏កើតឡើងជាច្រើនយ៉ាង បុគ្គលចាស់នោះ រមែងឃើញបានតែត្រឹមរូបធំៗ ដូចបុគ្គលងងឹតក្នុងវេលាយប់ ។*

អសារេ សារយោគញ្ញូ, មតិំ ន ត្វេវ វិន្ទតិ;

សរភោវ គិរិទុគ្គស្មឹ, អន្តរាយេវ សីទតិ។

បុគ្គលចាស់ដឹងនូវសេចក្ដីព្យាយាម ក្នុងលទ្ធិមិនមានខ្លឹម ថាលទ្ធិមានខ្លឹម រមែងមិនបាននូវប្រាជ្ញា តែងលិចចុះក្នុងសេចក្ដីអន្តរាយមិនខាន ដូចជាសត្វសរភៈ លិចចុះក្នុងជ្រោះនៃភ្នំ ។

ហីនជច្ចោបិ ចេ ហោតិ, ឧដ្ឋាតា ធិតិមា នរោ;
អាចារសីលសម្បន្នោ, និសេ អគ្គីវ ភាសតិ។

ជនបើទុកជាមានជាតិថោកថយ តែជាអ្នកមានការប្រឹងប្រែង មានប្រាជ្ញាបរិបូណ៌ដោយអាចារសីល រមែងរុងរឿងដូចជាភ្លើង ក្នុងរាត្រី ។

ឯតំ មេ ឧបមំ កត្វា, បុត្តេ វិជ្ជាសុ វាចយ;
សំវិរូឡ្ហេថ មេធាវី, ខេត្តេ ពីជំវ វុដ្ឋិយ។

សូមព្រះអង្គធ្វើសេចក្ដីនេះឯង ឲ្យជាគ្រឿងប្រៀបធៀបហើយញ៉ាំងពួករាជបុត្ត ឲ្យប្រតិស្ឋានក្នុងវិជ្ជាទាំងឡាយ ត្បិតអ្នកប្រាជ្ញតែងលូតលាស់ល្អ ដូចពូជដែលលូតលាស់ក្នុងស្រែក្នុងកាលដែលមានភ្លៀង ។

ពាក្យថា **តែបើក្នុងកាលជាខាងក្រោយ គឺកាលដែលខ្លួនចាស់ ធ្វើនូវសេចក្ដីព្យាយាមក្នុងកិច្ចការ** សេចក្ដីថា បើកុលបុត្រណាមិនធ្វើយោគៈគឺសេចក្ដីព្យាយាមក្នុងសិក្ខាដែលគប្បីសិក្សា ក្នុងកាលនៅក្មេងទេ ខាងក្រោយមក ទើបធ្វើក្នុងកាលខ្លួនចាស់ កុលបុត្រនឹងដល់សេចក្ដីទុក្ខ និងសេចក្ដីអន្តរាយដែលមានសភាពបែបនោះ ហើយលិចចុះ ក្នុងកាលជាខាងក្រោយ មិនអាចនឹងលើកខ្លួនឡើងវិញបាន ។ ពាក្យថា **បុគ្គលចាស់នោះ រមែងឃើញបានតែត្រឹមរូបធំៗ ដូចបុគ្គលងងឹតក្នុងវេលាយប់** សេចក្ដីថា ការងងឹតក្នុងវេលាយប់ បុគ្គលរមែងឃើញតែរូបធំៗ ដោយពន្លឺព្រះចន្ទជាដើម តែមិនអាចឃើញរូបល្អិត យ៉ាងណា កុលបុត្រដែលមិនបានសិក្សា មានប្រាជ្ញារវើរវាយ កាលភ័យយ៉ាងណាមួយកើតឡើង មិនអាចឃើញ

នូវកិច្ចដ៏ល្អិតសុខុម រមែងឃើញតែកិច្ចដែលគ្រោតគ្រាតប៉ុណ្ណោះ ក៏យ៉ាងនោះ ព្រោះហេតុនោះ ទ្រង់គួរឲ្យបុត្រទាំងឡាយរបស់ព្រះអង្គសិក្សារៀនសូត្រ ក្នុងកាលដែលនៅក្មេង ។

ពាក្យថា **ក្នុងលទ្ធិមិនមានខ្លឹម** សេចក្តីថា ក្នុងសម័យលោកាយតវេទ ( គម្ពីរសម្តែងគតិលោកដែលមានដំណើរសេចក្តីរឿងរយករយាកមិនគួរជឿ ឬគម្ពីរដែលមានសេចក្តីបដិសេធថា ឋានសួគ៌ឋាននរកមិនមាន ) ។ ពាក្យថា **រមែងមិនបាននូវប្រាជ្ញា** សេចក្តីថា សូម្បីសិក្សាដ៏ច្រើនហើយ រមែងមិនបានបញ្ញា ។ ពាក្យថា **ដូចជាសត្វសរភៈ លិចចុះក្នុងជ្រោះនៃភ្នំ** សេចក្តីថា ឈ្មោះថា **សរភៈ** (ក្តាន់ ឈ្លូស ប្រើស) កាលមកកាន់លំនៅរបស់ខ្លួន សម្គាល់ផ្លូវដែលនៅចន្លោះ ដែលមិនរាបស្មើថារាបស្មើ ហើយដើរមកដោយរហ័សត្រង់ជ្រោះភ្នំ តែងធ្លាក់ក្នុងរណ្តៅ ហើយលិចចុះក្នុងសេចក្តីអន្តរាយ រមែងមិនដល់លំនៅ យ៉ាងណា កុលបុត្រដែលមានសភាពបែបនោះ កាលរៀនយកនូវលោកាយតវេទៈដែលមិនមានសារៈ ដោយសម្គាល់ថាមានសារៈ រមែងដល់សេចក្តីវិនាសធំ ក៏យ៉ាងនោះ ។ ព្រោះហេតុនោះ សូមទ្រង់ឲ្យបុត្រទាំងឡាយរបស់ព្រះអង្គប្រកបក្នុងកិច្ចការ ដែលមានប្រយោជន៍ និងនាំមកនូវសេចក្តីចម្រើនហើយឲ្យសិក្សាចុះ ។

ពាក្យថា **រមែងរុងរឿងដូចជាភ្លើង ក្នុងរាត្រី** សេចក្តីថា បពិត្រមហារាជ មនុស្សខ្លះសូម្បីកើតមកក្នុងកំណើតថោកទាប តែជាអ្នកដល់ព្រមដោយគុណមានសេចក្តីព្យាយាមជាដើម រមែងរុងរឿង បីដូចជាគំនរភ្លើងក្នុងពេលរាត្រី ។

ពាក្យថា **សូមព្រះអង្គធ្វើសេចក្តីនេះឯង** សេចក្តីថា ព្រះអង្គចូរធ្វើការឧបមាគំនរភ្លើងក្នុងពេលរាត្រី ដែលទូលព្រះបង្គំបានពោលនេះ ហើយសូមទ្រង់ឲ្យបុត្រទាំងឡាយរបស់ព្រះអង្គតាំងនៅក្នុងវិជ្ជា និងឲ្យប្រកបក្នុងសិក្ខាដែលសមគួរនឹងសិក្សាចុះ ។ គ្រាប់ពូជរមែងលូតលាស់ក្នុងស្រែល្អ ក្នុងកាលដែលមានភ្លៀងធ្លាក់មកល្អ យ៉ាងណា កុលបុត្រដែលប្រកបក្នុងវិជ្ជាយ៉ាងនេះហើយ ជាអ្នកមានបញ្ញា រមែងលូតលាស់ និងចម្រើនដោយយស និងភោគៈ ក៏យ៉ាងនោះ ។

*ព្រះមហាសត្វសម្ដែងធម៌ដល់ព្រះរាជាយ៉ាងនេះ រហូតទល់ភ្លឺ ។ ចំណាំងប្លែករបស់ព្រះទេវីក៏បានស្ងប់រម្ងាប់ ។ ព្រះមហាសត្វកាលអរុណរះឡើងហើយ ក៏ញុំាងព្រះរាជាឲ្យតាំងនៅក្នុងបញ្ចសីល រួចទូន្មានប្រៀនប្រដៅដោយអប្បមាទធម៌ ទើបចេញទៅតាមបង្អួចទិសខាងជើង មួយអន្លើដោយហង្សសុមុខៈ ទៅកាន់ភ្នំចិត្តកូដ ។*

*ព្រះសាស្ដានាំព្រះធម្មទេសនានេះមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងកាលមុន អានន្ទក៏បានបរិច្ចាគជីវិតដើម្បីប្រយោជន៍តថាគតយ៉ាងនេះដូចគ្នា ហើយទ្រង់ប្រជុំជាតកថា*

**តទា លុទ្ទោ ឆន្នោ អហោសិ** *ព្រានក្នុងកាលនោះ បានមកជាឆន្នៈ*

**រាជា សារិបុត្តោ** *ព្រះរាជាបានមកជាសារីបុត្រ*

**ទេវី ខេមាភិក្ខុនី** *ព្រះទេវីបានមកជាខេមាភិក្ខុនី*

**ហំសបរិសា សាកិយគណោ** *បរិស័ទហង្សបានមកជាពួកសក្យរាជ*

**សុមុខោ អានន្ទោ** *ហង្សសុមុខៈ បានមកជាអានន្ទ*

**ហំសរាជា បន អហមេវ អហោសិំ** *ចំណែកស្ដេចហង្ស គឺ តថាគតនេះឯង ។*

*ហំសជាតក ចប់ ។*

*(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក វីសតិនិបាត បិដកលេខ ៦០ ទំព័រ ៩៣)*

*ថ្ងៃ ច័ន្ទ ១០ រោច ខែទុតិយាសាឍ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០*

*ថ្ងៃទី ០៦ ខែ សីហា ព.ស. ២៥៦២ គ.ស.២០១៨*

*ដោយស.ដ.វ.ថ*